ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការនិងដឹកជញ្ជូន

លេខ.២២៣.....ប្រក.សក.បធ

ភ្នំពេញ-ថ្ងៃទី០៥ ខែ ០៧ ឆ្នាំ២០០៤

# ប្រកាស

## ស្តីពីការតែងតាំងមន្ត្រី-រាជការ

## រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

-បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ មករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន

-បានឃើញអនុក្រឹត្យលេខ ១៤/អនក្រ.បក ចុះថ្ងៃទី ៣ មិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន

-បានឃើញអនុក្រឹត្យលេខ ៦៤/អនក្រ.បក ចុះថ្ងៃទី ៩ កក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់និងគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេរភាគី ច្រកទ្វារតំបន់ព្រំដែន និង ច្រកទ្វារកំពង់ផែសមុទ្រ នៅ ទូទាំងព្រះរាជាណាចក្រកម្ពុជា

-យោងអនុក្រឹត្យលេខ ៨១អនក្រ ចុះថ្ងៃទី៣០-០៨-៩៩ ស្តីពីតួនាទីភារកិច្ចរបស់ភ្នាក់ងារកម្ពុជានាវាចរ "កាំសាប"

-យោងលិខិតលេខ ៤១៨ កស ចុះថ្ងៃទី ២៣.០៦.២០០៤ របស់ កាំសាប

-យោងតាមការចាំបាច់របស់កាំសាប

## សំរេច

**ប្រការ១:** តំណាងកាំសាប ត្រូវបានចាត់ជាមន្ត្រីសំរបសំរួលបែបបទចេញ-ចូលនាវាអន្តរជាតិនៅច្រកក្អមសំណ ។

**ប្រការ២:** តំណាងកាំសាប មានតួនាទីជំនួសមុខអោយក្រសួង កំពង់ផែ ក្នុងការធ្វើទំនាក់ទំនងជាមួយសមត្ថកិច្ច ដើម្បីធានាបាននូវភាពរលូន និង ប្រសិទ្ធភាព ក្នុងដំណើរចេញ-ចូលរបស់នាវាមានលក្ខណៈជាអន្តរជាតិ ។

**ប្រការ៣:** តំណាងកាំសាប ត្រូវធ្វើរបាយការណ៍ទៀងទាត់និងជាប្រចាំមកក្រសួង ដែលជាអាណាព្យាបាលជាបន្ទាន់ នូវរាល់បាតុភាពអសកម្មទាំងឡាយដែលកើតមានករណីជាយថាហេតុ ។

**ប្រការ៤:** នាយកខុទ្ទកាល័យអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល-អង្គភាពពាក់ព័ន្ធនិងអគ្គនាយក "កាំសាប" មានភារកិច្ចចាត់តាំងមន្ត្រីចុះអនុវត្តការងារតាមខ្លឹមសារប្រកាសនេះអោយមានប្រសិទ្ធភាព ។

**ចំលងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី "ជ្រាបជាពត៌មាន"
-ក្រសួងមហាផ្ទៃ -
-សាលាខេត្តកណ្តាល -
-សាលាខេត្តព្រៃវែង -
-កាំសាប -
-កំពង់ផែភ្នំពេញ -
-សមត្ថកិច្ចច្រកទ្វារព្រំដែនក្អមសំណរ "ជ្រាបជាពត៌មាននិងអនុវត្តន៍"
-ឯកសារ- កាលប្បវត្តិ

រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

ត្រាំ អ៊ីវទឹក